ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ៤៨ ២០/២០២៥ កបទ.សអ

## សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងនូវការព្រួយបារម្ភជាខ្លាំងចំពោះសេចក្តីរាយការណ៍ថ្មីៗនេះ នៅលើគេហទំព័រផ្លូវការនានារបស់ប្រទេសថៃ ជាពិសេសគេហទំព័ររបស់ការិយាល័យអ្នកនាំពាក្យកងទ័ពជើងទឹកថៃ និងទីបញ្ជាការដ្ឋានការពារព្រំដែនច័ន្ទបុរី-ត្រាត ព្រមទាំងកាសែត The Nation (ប្រទេសថៃ) ដែលហាក់ដូចបង្ហាញថា ប្រជាពលរដ្ឋខ្មែរកំពុងតែ «**ឈ្លានពាន**» ទឹកដីថៃ នៅទីតាំងចំនួន១៧ ស្ថិតនៅតំបន់ពីខេត្តពោធិ៍សាត់ ដល់ខេត្តកោះកុង រួមទាំងតំបន់ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៃប្រទេសកម្ពុជា ដែលស្ថិតនៅទល់មុខនឹងស្រុកមឿង ខេត្តត្រាត នៃប្រទេសថៃ។

២. ជារឿងសំខាន់ដែលត្រូវទទួលស្គាល់ការពិតថា ខណៈពេលដែលប្រទេសទាំងពីរមិនទាន់បានកំណត់ខណ្ឌសីមានៅតំបន់មួយចំនួននៃព្រំដែនរួមគ្នា ប្រជាជនទាំងសងខាងបានរស់នៅ និងបង្កបង្កើនផលអស់ជាច្រើនទសវត្សរ៍មកហើយ នៅលើដីក្នុងតំបន់ដែលមិនទាន់បានកំណត់ព្រំដែន។ ការណ៍នេះបានបង្កឱ្យមានជម្លោះ ឬការខ្វែងគំនិតគ្នា ដែលភាគីទាំងពីរបានដោះស្រាយប្រកបដោយស្មារតីមិត្តភាព តាមរយៈគណៈកម្មាធិការព្រំដែនទូទៅ និងបានឯកភាពបញ្ជូនបញ្ហាស្មុគស្មាញទាំងនេះទៅគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក (JBC) ដើម្បីដោះស្រាយ ស្របតាមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការវាស់វែង និងខណ្ឌសីមាព្រំដែនគោក ដែលត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ២០០០ (MOU-2000)។

៣. នៅក្នុងកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៥ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមុនៗ ដើម្បីជៀសសកម្មភាព ដែលអាចបង្កើនភាពតានតឹង ឬពង្រីកតំបន់ជម្លោះ។ កម្ពុជាបាន និងកំពុងអត់ធ្មត់ជាទីបំផុត និងអនុវត្តយ៉ាងតឹងរ៉ឹងចំពោះលក្ខខណ្ឌនៃកិច្ចព្រមព្រៀងបទឈប់បាញ់ តាមសេចក្តីប្រាថ្នាដែលភាគីទាំងពីរបានលើកឡើងដូចគ្នាថា នេះគឺជាពេលដែលទាំងសងខាងគួរតែរួមគ្នាខិតខំលើក




អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

កម្ពស់បរិយាកាសអំណោយផលសម្រាប់ការបន្ធូរបន្ថយភាពតានតឹងបន្ថែមទៀត កសាងទំនុកចិត្តរវាងគ្នាទៅវិញទៅមក ដើម្បីឆ្ពោះទៅរកប្រក្រតីភាពឡើងវិញ។

៤. ហេតុនេះ វាមិនមែនជាកាយវិការស្លាបនាទេ ដែលមានការបំផុសបញ្ហាដូចបានប្រកាសជាសាធារណៈ ដោយកងទ័ពជើងទឹកថៃ ដែលបញ្ហានេះត្រូវបានដោះស្រាយសមស្របរួចហើយ ជាមួយនឹងការប្រាស្រ័យទាក់ទងគ្នាចុងក្រោយ នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០២២។ កម្ពុជាសូមអំពាវនាវឱ្យភាគីថៃលើកបញ្ហានេះមកដោះស្រាយនៅក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ដែលគ្រោងនឹងជួបគ្នានៅខែក្រោយ។

៥. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួន និងឥតងាករេរបស់កម្ពុជា ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយមិត្តភាពចំពោះវិវាទព្រំដែនជាមួយប្រទេសថៃ ក៏ដូចជាជាមួយប្រទេសជិតខាងទាំងអស់ តាមសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ទន្ទឹមនឹងការប្តេជ្ញាចិត្តរក្សាគោលជំហររបស់ខ្លួនថា ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយការប្រើកម្លាំងនោះទេ៕

ថ្ងៃព្រហស្បតិ៍ ៣កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥

*Unofficial Translation*

No. SM 20/2025 MFA.IC

## Statement of the Ministry of Foreign Affairs and International Cooperation of The Kingdom of Cambodia

1. The Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia wishes to express grave concern over the latest reporting in various Thai official websites, in particular the website of the Spokesperson's Office of the Royal Thai Navy and the Chanthaburi–Trat Border Defense Command, and The Nation (Thailand), which cast Cambodian citizens literally "invading" Thailand in 17 locations along the areas adjacent to Cambodia's provinces of Pursat and Koh Kong, including in Veal Veng District, Pursat Province of Cambodia, opposite Mueang District, Trat Province.

2. It is important to acknowledge the fact that, while both countries have yet to demarcate several segments of the shared border, people on both sides have lived on and cultivated the lands for decades in many un-demarcated areas. This has given rise to disputes or differences that both sides have been able to amicably addressed through the General Border Committee, and agreed to refer the complicated issues to the Joint Commission for Demarcation of Land Boundary (JBC) for settlement, in accordance with the Memorandum of Understanding on the Survey and Demarcation of Land Boundary signed in 2000.

3. At the Special General Border Committee Meeting which was concluded on 10 September 2025, both sides reaffirmed commitment made in earlier meetings to avoid actions that could escalate tensions or expand the area of disputes. Cambodia has been exercising utmost restraint and strictly complying with the ceasefire terms, in line with shared aspiration expressed that it is now time for both sides to jointly endeavour to promote conducive atmosphere for further de-escalation, mutual confidence building, and work toward normalcy.

4. Therefore, it is unconstructive to hype up the issue such as one cited in the recent public release of Royal Thai Navy, which has already been appropriately addressed, with the last communication made on 1 February 2022. Cambodia calls on Thai side to resolve the issue through the JBC, which is due to meet next month.

5. The Ministry of Foreign Affairs and International Cooperation wishes to reiterate Cambodia's consistent and unwavering commitment to seeking amicable resolution to all border disputes with Thailand, as with all its neighbours, through peaceful means in accordance with international law, while remaining resolute in upholding its principled position that borders must not be changed by force.

Phnom Penh, 25 September 2025